**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**

**នាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក**

**លេខ :** ០០២៨/២១ **អគរ/ន.ហប**

ថ្ងៃចន្ទ ១២កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១

**ជម្រាបជូន**

- **លោកប្រធានលេខាធិការដ្ឋាន លោកប្រធាននាយកដ្ឋាន លោកនាយកសាលាជាតិគយ**
- **លោក លោកស្រីប្រធានសាខា និងការិយាល័យគយនិងរដ្ឋាករ**

**កម្មវត្ថុ÷** ស្តីពីការប្រើគោរមងារ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

**យោង ÷** ព្រះរាជក្រឹត្យលេខ នស/រកត/០១២១/០៦៦ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២១។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន លោក លោកស្រី មេត្តាជ្រាបថា **ឯកឧត្តមបណ្ឌិត គុណ ញឹម** ត្រូវបាន **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** សព្វព្រះរាជហឫទ័យ ត្រាស់បង្គាប់តែងតាំងជា **រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី** បន្ថែមលើមុខងារបច្ចុប្បន្ន។ ក្នុងន័យនេះ នាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក សូមជម្រាបជូនអំពីការប្រើគោរមងារក្នុងលិខិតដែលត្រូវគោរពជូន ឬចុះហត្ថលេខាដោយឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ដូចខាងក្រោម÷

១-សេចក្តីគោរពជូនឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី

**សូមគោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**

**អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**

H.E Minister Attached to the Prime Minister

Director General of the General Department of Customs and Excise

២-គោរមងាររបស់ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ក្នុងការចុះហត្ថលេខា

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**

**អគ្គនាយកគយនិងរដ្ឋាករកម្ពុជា**

Minister Attached to the Prime Minister

Director General of the General Department of Customs and Excise

៣-គោរមងារសង្ខេបប្រើប្រាស់ក្នុងខ្លឹមសារលិខិត ឬអត្ថបទ

**ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ឬ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូ**

សេចក្តីដូចបានជម្រាបជូនខាងលើ សូមលោក លោកស្រី មេត្តាជ្រាប និងអនុវត្តចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។ សូម លោក លោកស្រី ទទួលនូវការគោរពរាប់អានពីខ្ញុំ

**ប្រធាននាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក**

**ទុំ_វណ្ណា**

**ចម្លងជូន÷**

-លោក លោកស្រី អគ្គនាយករង នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

“ដើម្បីគោរពជូនជ្រាប”

-ឯកសារ-កាលប្បវត្តិ

អាសយដ្ឋាន៖ លេខ ៦-៨ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ កម្ពុជា

ទូរស័ព្ទ / ទូរសារ: (៨៥៥-២៣) ២១៤ ០៦៥ / ៧២៥ ១៨៧ / ២១២ ៤៥៧ / E-mail: info-pru@customs.gov.kh